# របាយការណ៍សង្ខេប
# សម្រាប់វេទិកាសន្និសីទសារព័ត៌មាន ស្តីពី
# "វឌ្ឍនភាព និងទិសដៅការងាររបស់ក្រុមប្រឹក្សាខេត្តប៉ៃលិន"
## ដោយឯកឧត្តម ជា ចាន់ឌិន ប្រធានក្រុមប្រឹក្សាខេត្តប៉ៃលិន
ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

**ជាបឋម** !

- សូមក្រាបថ្វាយបង្គំ **សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
- សូមគោរព **សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ**
- លោក លោកស្រី អ្នកសារព័ត៌មានទាំងអស់ដែលមាន វត្តមាននៅក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ។

ក្នុងនាមក្រុមប្រឹក្សាខេត្ត និងប្រជាពលរដ្ឋនៅក្នុងខេត្តប៉ៃលិន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលរៀបចំ និងអនុញ្ញាតឱ្យរូបខ្ញុំ បានចូលរួមសន្និសីទសារព័ត៌មានស្តីពី **"វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តប៉ៃលិន"** ដើម្បីបង្ហាញជូនសាធារណជន តាមរយៈយន្តការដែលមានស្រាប់ ក្នុងការជម្រុញ និងគាំទ្រប្រកបដោយប្រសិទ្ធភាពការងារនៅនឹងមូលដ្ឋាន នៃខេត្តប៉ៃលិនរបស់យើងខ្ញុំ។

ជាថ្មីម្តងទៀត ក្នុងនាមរដ្ឋបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្តប៉ៃលិនទាំងមូល ខ្ញុំសូមយកឱកាសនេះសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវចក្ខុវិស័យ និងគោលនយោបាយ ដ៏ត្រឹមត្រូវតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ធ្វើឱ្យសេដ្ឋកិច្ចជាតិ មានកំណើនខ្ពស់ ក្នុងរយៈពេលយូរ និងរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលអាចនឹងបន្តឈានឆ្ពោះប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅពេលអនាគត។ ជាមួយគ្នានេះ គោលនយោបាយ **ឈ្នះ ! ឈ្នះ** ! របស់ **សម្តេចតេជោ** ពិតជាបានធ្វើឱ្យប្រទេសជាតិ ទទួលបាននូវសុខ

សន្តិភាពពេញបរិបូរណ៍ ធ្វើឱ្យប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស ទទួលបាននូវសិទ្ធិសេរីភាព គ្មានការភ័យខ្លាច សេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅរបស់ប្រជាជនមានការរីកចម្រើនឥតឈប់ឈរ ធ្វើឱ្យសង្គមទាំងមូលមានភាពសុខដុមរមនា នៅគ្រប់ទីកន្លែងទូទាំងប្រទេស។ ក្នុងនោះដែរ ខេត្តប៉ៃលិន ក៏បានទទួលនូវមនុញ្ញផល យ៉ាងច្រើនពីសន្តិភាព "**អរគុណសន្តិភាព**" រហូតមកដល់បច្ចុប្បន្ន ដោយបានប្រែក្លាយទឹកដីខេត្តប៉ៃលិន ពីតំបន់សមរភូមិ គួរឱ្យភ័យខ្លាច និងគ្មានការអភិវឌ្ឍក្នុងអំឡុងទសវត្សទី៨០ មកជាតំបន់ដែលមានការអភិវឌ្ឍលើគ្រប់វិស័យ ពីតំបន់ដែលពោរពេញដោយគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលបន្សល់ទុកពីភ្លើងសង្គ្រាម មកជាចំការដំណាំប្រកបដោយពណ៌បៃតងស្រស់ ស្ទើរពេញមួយឆ្នាំ និងជារមណីយដ្ឋានទេសចរណ៍ដែលមានទេសចរណ៍មកសម្រាកលំហែរ ស្ទើរគ្រប់រដូវកាល រីឯតំបន់ព្រំដែន ក៏បានប្រែក្លាយជាព្រំដែនមិត្តភាព និងមានកិច្ចសហប្រតិបត្តិការ រវាងខេត្តជាប់ព្រំដែន ដោយមានប្រជាពលរដ្ឋរស់នៅ ជារបងយ៉ាងច្រើនកុះករ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទឱ្យតំណាងមន្ត្រីរាជការ និងប្រជាពលរដ្ឋខេត្តប៉ៃលិន ខ្ញុំសូមគោរពថ្លែងអំណរគុណជាអតិបរិមា ចំពោះ**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានយកចិត្តទុកដាក់ ដោះស្រាយជីវភាពរស់នៅ របស់ប្រជាជន តាមកម្មវិធីផ្សេងៗជាអាទិ៍។ ជាក់ស្តែងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១នេះ កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ អនុវត្តបានចំនួន ១០ ៤៤៩ នាក់ សរុបទឹកប្រាក់ ៦០១ ៣៥០ ០០០ (ប្រាំមួយរយមួយលាន បីរយហាសិបពាន់រៀល) និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ បានចំនួន ៥ ៥៥៥ គ្រួសារ សរុបជាទឹកប្រាក់ ១៥ ៣៨២ ៩៦៥ ០០០ រៀល (ដប់ប្រាំពាន់ បីរយប៉ែតសិបពីរពាន់លាន ប្រាំបួនរយ ហុកសិបប្រាំពាន់រៀល) និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជំនួយសង្គម ក្នុងអំឡុងពេលបិទខ្ទប់ចំនួន ៣៥ គ្រួសារ សរុបទឹកប្រាក់ ១០ ៣៥០ ៩០០ (ដប់លាន បីរយ ហាសិបពាន់ ប្រាំបួនរយរៀល)។ ចំពោះការជួយអន្តរាគមន៍ឧបត្ថម្ភសង្គ្រោះប្រជាជនបណ្តាលមកពីគ្រោះមហន្តរាយទឹកជំនន់ទឹកភ្លៀង ខ្យល់កន្ត្រាក់ និងគ្រោះធម្មជាតិផ្សេងៗ បានចំនួន ៣៩ ៦២០ (បីម៉ឺនប្រាំបួនពាន់ ប្រាំមួយរយម្ភៃ) គ្រួសារ លើឃុំ សង្កាត់ទាំងប្រាំបី និងបានស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងដំណាំកសិកម្មដែលរងការខូចខាត។ ដោយឡែកការអនុវត្តនូវវិធានការនានារបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាព នៃការងារប្រយុទ្ធប្រឆាំង ការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលខេត្តប៉ៃលិន បានប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់។ ជាក់ស្តែងរដ្ឋបាលខេត្ត បានធ្វើសកម្មភាពជួយឧបត្ថម្ភជីវភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងពលករដែលវិលត្រឡប់មកពីប្រទេសថៃ បានជាបន្តបន្ទាប់ និងបានរៀបចំ ឱ្យមានជាមណ្ឌលចត្តាឡីស័ក មណ្ឌលព្យាបាលជំងឺ និងផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋ ដូចខាងក្រោម៖

- អ្នកមកធ្វើចត្តាឡីស័ក សរុបចំនួន ១៩ ០២៨ នាក់ ស្រី ៨ ៣៣៣ នាក់
- អ្នកឆ្លងជំងឺកូវីដ-១៩ សរុបចំនួន ២ ៨៩៦ នាក់ ស្រី ១ ៣៧២ នាក់

- ព្យាបាលជំងឺកូវីដ-១៩ ជាសះស្បើយ សរុបចំនួន ២ ៨១៦ នាក់ ស្រី ១ ៣៤៧ នាក់
- អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ សរុបចំនួន ០៨ នាក់ ស្រី ០៣ នាក់

**ក.ប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំឡើង** បានចាក់វ៉ាក់សាំងសរុបចំនួន ៤០ ៩៩៦ នាក់ ក្នុងនោះមាន៖

- ចាក់ដូសទី១ ចំនួន ៤៤ ៨០១ នាក់
- ចាក់ដូសទី២ ចំនួន ៤៣ ២៨៦ នាក់
- ចាក់ដូសទី៣ ចំនួន ២០ ៥៥៩ នាក់
- ចាក់លើសផែនការ ចំនួន ៣ ៨០៥ នាក់

**ខ.កុមារចាប់ពីអាយុ១២ ដល់ក្រោម ១៨ឆ្នាំ** សរុបចំនួន ១០ ០០៩ នាក់

- ចាក់ដូសទី១ ចំនួន ៩ ៤៥២ នាក់
- ចាក់ដូសទី២ ចំនួន ៩ ២៦៦ នាក់
- ចាក់ដូសទី៣ ចំនួន ២ ៧២៤ នាក់
- អ្នកមិនបានចាក់ ចំនួន ៥៥៧ នាក់

**គ.កុមារចាប់ពីអាយុ០៦ដល់ក្រោម១២ឆ្នាំ** សរុប ៩ ៥០៩ នាក់

- ចាក់ដូសទី១ ចំនួន ១០ ១៧៦ នាក់
- ចាក់ដូសទី២ ចំនួន ១០ ០៤៥ នាក់
- អ្នកមកចាក់លើសផែនការ ចំនួន ៦៦៧ នាក់

**ឃ-កុមារអាយុ០៥ឆ្នាំ** ចំនួនសរុប ១ ៩២៥ នាក់

- ចាក់ដូសទី១ ចំនួន ១ ៤២៧ នាក់
- ចាក់ដូសទី២ ចំនួន ១ ២៣១ នាក់
- កុមារមិនបានចាក់ ចំនួន ៤៩៨ នាក់

**ង-កម្មករ កម្មការនី បុគ្គលិកក្រុមហ៊ុន រោងចក្រ** សរុបចំនួន ៨ ១៦៨ នាក់

- ចាក់ដូសទី១ ចំនួន ៥ ៣០៣ នាក់
- ចាក់ដូសទី២ ចំនួន ៥ ៣០៥ នាក់
- អ្នកដែលមិនបានចាក់ ចំនួន ២ ៨៦៣ នាក់

**ច-អតីតយុទ្ធជនសរុប** ចំនួន ១ ៥១៥ នាក់

- ចាក់ដូសទី១ ចំនួន ៨៥២ នាក់
- ចាក់ដូសទី២ ចំនួន ៨៥២ នាក់
- អ្នកដែលមិនបានចាក់ ចំនួន ៦៦៣ នាក់

**ជ-ប្រជាពលរដ្ឋខ្មែររស់នៅផ្សារព្រំដែនថៃ** បានចាក់វ៉ាក់សាំងសរុបចំនួន ៦០០ នាក់ អ្នកមិនបានចាក់ចំនួន ៥១៨ នាក់។

ឃ-ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិលក្នុងខេត្ត ចាក់វ៉ាក់សាំងដូសទី៣ សរុបចំនួន ២ ៩៣៤ នាក់ និងបានចាក់វ៉ាក់សាំង ដូសទី៤ សរុបចំនួន ៩៨០ នាក់។

**សរុបវ៉ាក់សាំងដែលចាក់នៅទូទាំងខេត្តបានចំនួន ១៧៩ ២៤៣ ដូស (គិតត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២)។**

ជាមួយនេះ រដ្ឋបាលខេត្តប៉ៃលិន សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម នាយឧត្តមសេនីយ៍ អ៊ី ឈាន រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តប៉ៃលិន** ដែលលោកតែងតែ បានឧបត្ថម្ភ គាំទ្រយ៉ាងពេញទំហឹងក្នុងការដឹកនាំ និងការអភិវឌ្ឍនៅខេត្តប៉ៃលិន ជារៀងរហូតមក។

**១-អំពីស្ថានភាពទូទៅ**

ខេត្តប៉ៃលិន ស្ថិតនៅភាគពាយព្យ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានព្រំប្រទល់ខាងលិចទល់នឹងខេត្តចន្ទបុរី នៃព្រះរាជាណាចក្រថៃ ខាងកើតទល់នឹងស្រុករតនៈមណ្ឌល ខាងជើងទល់នឹងស្រុកកំរៀង និងខាងត្បូងទល់នឹងស្រុកសំឡូត នៃខេត្តបាត់ដំបង។ ខេត្តប៉ៃលិន មានផ្ទៃដីសរុប ១០៦២ គីឡូម៉ែត្រការ៉េ មានក្រុង ០១ និងស្រុក ០១ បែងចែកជា ០៨ ឃុំ សង្កាត់ ស្មើនឹង ៩០ ភូមិ។ ដែលមានប្រជាពលរដ្ឋសរុបចំនួន ១៦ ៥៨៨ គ្រួសារ ស្មើនឹងមនុស្សរាយសរុបចំនួន ៧១ ៤៨៣ នាក់ ស្រី ៣៤ ១៥៣ នាក់ អាយុ១៨ឆ្នាំឡើងចំនួន ៤៤ ៨៧៦ នាក់។ ក្នុងនោះមានៈ

- ស្នាក់នៅជាអចិន្ត្រៃយ៍ ចំនួន ១៦ ២៣៧ គ្រួសារ
- ស្នាក់នៅជាលក្ខណៈបណ្តោះអាសន្ន ចំនួន ៦៦៩ គ្រួសារ
- ចំណាកស្រុកទៅក្រៅខេត្តមាន ចំនួន ៤ ២៦៥ នាក់

បើប្រៀបធៀបនឹងឆ្នាំ២០២០ ប្រជាពលរដ្ឋចំណាកស្រុកមានការថយចុះ។ ដោយឡែកជនបរទេសបានមកស្នាក់នៅក្នុងខេត្តមានចំនួន ៨២៨ នាក់ មាន ៣២ សញ្ជាតិ ក្នុងនោះស្នាក់នៅរយៈពេលវែងចំនួន ១១០ នាក់ស្រី ៣០ នាក់ ស្នាក់នៅ រយៈពេលខ្លីចំនួន ៧១៨ នាក់ ស្រី ៦៦៨ នាក់។

ខេត្តប៉ៃលិន មានព្រំដែនប្រវែង ៤៣ គីឡូម៉ែត្រ ជាប់នឹងខេត្តច័ន្ទបុរី នៃព្រះរាជាណាចក្រថៃ និងមានច្រកទ្វារព្រំដែនចំនួន ០១ គឺច្រកទ្វារព្រំដែនអន្តរជាតិព្រំ។

សណ្ឋានដីខេត្តប៉ៃលិន ចែកជាពីរតំបន់សំខាន់គឺ តំបន់ខ្ពស់ និងតំបន់ទំនាប។ តំបន់ខ្ពស់សំដៅលើតំបន់ខ្ពង់រាប និងតំបន់ព្រៃភ្នំ ដែលជាតំបន់សម្រាប់ធ្វើចំការឈើហូបផ្លែ និងដំណាំឧស្សាហកម្មផ្សេងៗ។ ចំណែកឯតំបន់ទំនាប ភាគច្រើនជាវាលស្រែ និងទំនាបលិចទឹក នៅរដូវវស្សា ហើយមានតែនៅក្នុងស្រុកសាលាក្រៅតែប៉ុណ្ណោះ។ ដោយសារស្ថានភាពភូមិសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចរបស់ខេត្ត គឺពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ព្រោះប្រជាពលរដ្ឋប្រមាណ ៧០% ប្រកបមុខរបរកសិកម្ម ចំពោះវិស័យផ្សេងៗទៀតដូចជា វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម និងការវិនិយោគនានា នៅមិនទាន់មានការរីកចំរើនខ្លាំងនៅឡើយ។

**២-វឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តប៉ៃលិន**

**២.១-អំពីក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្តប៉ៃលិន អាណត្តិទី៣ មានសមាជិកសរុបចំនួន ១៥ នាក់ ស្រី ៣ នាក់ ហើយត្រូវបានប្រកាសចូលកាន់មុខតំណែងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩។ ក្រុមប្រឹក្សាក្រុង ស្រុក មានចំនួន ៣០ នាក់ ស្រី ០៧ នាក់ និងក្រុមប្រឹក្សា ឃុំ សង្កាត់ មានចំនួន ៥២ នាក់ ស្រី ១៥ នាក់។ ក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សាខេត្ត មានគណៈកម្មាធិការដែលជាកាតព្វកិច្ចចំនួន ០៣ គណៈកម្មាធិការ គឺៈ

- **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត** មានសមាសភាពចំនួន ៤៣ នាក់ ស្រី ០៥ នាក់ ក្នុងនោះមានសមាសភាពជាក្រុមប្រឹក្សាខេត្តចំនួន ០២ នាក់។ គណៈ កម្មាធិការនេះ បានប្រជុំចំនួន ០២ លើក ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខេត្ត។
- **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារខេត្ត** មានសមាសភាពចំនួន ១៧ នាក់ ស្រី ១២ នាក់ ក្នុងនោះ មានសមាសភាពជាក្រុមប្រឹក្សា ចំនួន ០២ នាក់។ គណៈកម្មាធិការនេះ អនុវត្តការងារសម្រេចបានលទ្ធផលដូចខាងក្រោមៈ
  - ➢ បានរៀបចំកិច្ចប្រជុំសាមញ្ញ ចំនួន ៣០ លើក
  - ➢ បានចូលរួមជាមួយគណៈអភិបាលខេត្ត ធ្វើសកម្មភាពចុះសួរសុខទុក្ខ ផ្សព្វផ្សាយវិធានការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងចែកអំណោយដល់ប្រជាពលរដ្ឋទីទ័លក្រ ខ្វះខាតជីវភាពក្នុងដំណាក់កាលកូវីដ និងជួបគ្រោះមហន្តរាយដោយជំនន់ទឹកភ្លៀង និងខ្យល់កន្ត្រាក់ នៅតាមបណ្តាឃុំ សង្កាត់ទាំង០៨ នៃខេត្តប៉ៃលិន ចំនួន ៤៥ លើក ជូនដល់ប្រជាពលរដ្ឋចំនួន ៤ ៨៤៣ គ្រួសារ ក្នុងនោះ ជាខ្មែរឥស្លាមចំនួន ១១០ គ្រួសារ
  - ➢ បានចុះសួរសុខទុក្ខក្មេងស្រីចំនួន០៣នាក់ នៅមជ្ឈមណ្ឌល ជួយស្រ្តី និងកុមារ ដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងប្រគល់ឱ្យសាច់ញាតិត្រឡប់ទៅស្រុកកំណើតវិញរៀងៗខ្លួន
  - ➢ បានចុះសួរសុខទុក្ខ និងនាំយកអំណោយស្បៀងអាហារ គ្រឿងឧបភោគបរិភោគ ទៅឧបត្ថម្ភជូនកុមារកំព្រានៅក្នុងមណ្ឌលកុមារកំព្រាខេត្តប៉ៃលិន ចំនួន ០២ លើក
  - ➢ បានចុះសួរសុខទុក្ខ និងចែកអំណោយដល់ស្រ្តីទើបសម្រាលកូនរួចចំនួន ០៦ លើក
  - ➢ បានចុះសួរសុខទុក្ខប្រជាពលរដ្ឋក្រីក្រ និងរងគ្រោះធម្មជាតិទឹកជំនន់ ដោយអប់រំគាត់ឱ្យបេះអនាម័យ លាងដៃ និងសាប៊ូ ឬអាល់កុល ដែលឱ្យបានញឹកញាប់ ពាក់ម៉ាស់ការពារពេលទៅទីកន្លែងប្រជុំជន ដើម្បីការពារការឆ្លងវីរុសកូវីដ-១៩ និងចែកអំណោយឃុំ សង្កាត់ទាំង៨ ចំនួន១៧លើក
  - ➢ បានចុះសួរសុខទុក្ខ និងជូនស្រ្តីទៅមន្ទីរពេទ្យ ចំនួន ២៣ លើក

- បានបើកវគ្គផ្សព្វផ្សាយស្តីពីការលើកកម្ពស់សុខភាពស្ត្រី និងកុមារ និងបណ្តុះបណ្តាលជំនាញកែច្នៃចំណី អាហារ កាត់ដេរ សំអាងកាយ និងតម្បាញ ចំនួន ១១ វគ្គ ដោយមានសិក្ខាកាមចូលរួមចំនួន ២៧៦ នាក់ ក្នុងនោះស្រី ២៤០ នាក់
- បានបញ្ជូនកុមាររងគ្រោះដោយអំពើសញ្ចារកម្ម អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ អំពើជួញដូរផ្លូវភេទ ចំនួន ០៥ លើក ដែលមានកុមារចំនួន ១១នាក់ ក្នុងនោះកុមារា ០១ នាក់ ទៅ អង្គការ SOS បាត់ដំបង អង្គការមេត្រីអន្តរជាតិ នៅរាជធានីភ្នំពេញ អង្គការ ខេ អិន ខេត្តបាត់ដំបង និងបញ្ជូនយុវនារី ០២ នាក់ទៅឪពុក ម្តាយវិញ
- បានចុះជួយអន្តរាគមន៍ករណីហិង្សាលើស្ត្រី និងកុមារចំនួន០៥ករណី
- បានចុះតាមដានកុមារសមាហរណកម្ម មកពីអង្គការផ្សេងៗចំនួន ៨ ករណី មានអង្គការ អេស អូ អេស(SOS) ចំនួន ២ ករណី អង្គការមាតុភូមិកុមារអន្តរជាតិចំនួន ២ ករណី អង្គការម្លប់ឬស្សីចំនួន ១ ករណី អង្គការ ខេ អិន ខេ ចំនួន ១ ករណី អង្គការហាហ្គា ចំនួន ១ ករណី និងអង្គការ អាម កម្ពុជា ចំនួន ១ ករណី
- បានបញ្ជូនយុវជនជាប់សារធាតុញៀនទៅស្តារនីតិសម្បទា នៅមណ្ឌលភ្នំបាក់ ខេត្តបន្ទាយមានជ័យ ចំនួន ០១ ករណី
- បានចុះធ្វើការប៉ាន់ប្រមាណរហ័ស នៅតាមមណ្ឌលកុមារថែទាំយូរអង្វែង ចំនួន ០៥ មណ្ឌល កុមារក្រោមអាយុ ១៨ឆ្នាំ ចំនួន ១៣៣ នាក់
- បានសហការ ចុះអប់រំសុខភាព តាមសហគមន៍ លើប្រជាជនចំណាកស្រុកចំនួន ២៨ លើក ដែលមានអ្នកចូលរួមចំនួន ៣ ៨៩៦ នាក់ ស្រី ១ ៩៧៣ នាក់ និងលើប្រជាជនស្នាក់នៅជា អចិន្ត្រៃយ៍តាមភូមិ ដែលមានប្រធានបទស្តីពី "ការបង្ការជំងឺឆ្លង(អេដស៍ របេង គ្រុនចាញ់ គ្រុនឈាម គ្រុន ឈីក ជំងឺកូវីដ-១៩) និងការថែទាំសុខភាពមាតាទារក កុមារ និងអាហាររូបត្ថម្ភ" ចំនួន ៤៨ លើក ដែលមានអ្នកចូលរួមចំនួន ១ ៩៥៤ នាក់ ស្រី ១ ៥៦៣ នាក់
- បានបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជំងឺអេដស៍ និងគ្រឿងញៀន និងលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត ចំនួន ០២ លើក មានសិក្ខាកាមចូលរួមចំនួន ២០ នាក់ ស្រី ១១ នាក់
- បានសហការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទចំនួន ០១ ករណី ឃាត់ខ្លួនជនសង្ស័យ ចំនួន ០១ នាក់ កសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តដើម្បីចាត់ការតាមនីតិវិធី
- បានសង្គ្រោះក្មេងស្រីរងគ្រោះ ជាអានីតិជនអាយុក្រោម ១៨ ឆ្នាំ ចំនួន ០១ លើក មានក្មេងស្រីចំនួន ០៥ នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ច។

- **គណៈកម្មាធិការលទ្ធកម្មខេត្ត** មានសមាសភាពចំនួន ០៩ នាក់ ស្រី ០២ នាក់ ក្នុងសមាសភាពជាក្រុមប្រឹក្សាខេត្ត ចំនួន០៣ នាក់ ស្រី ០១ នាក់។ គណៈកម្មាធិការនេះអនុវត្តតួនាទីរបស់ខ្លួន សម្រេចបានលទ្ធផលដូចខាងក្រោម៖
  - ➢ ប្រជុំបើកសំណើពិគ្រោះថ្លៃ (ទំនិញ) ចំនួន០៥លើក ស្មើនឹង ១២គម្រោង
  - ➢ ប្រជុំបើកសំណើដេញថ្លៃ (ទំនិញ) ចំនួន០១លើក ស្មើនឹង ០២គម្រោង
  - ➢ ប្រជុំបើកសំណើដេញថ្លៃ (សំណង់) ចំនួន០១លើក ស្មើនឹង ០១គម្រោង
  - ➢ ប្រជុំចរចាថ្លៃ (ផ្លូវ) ចំនួន០២លើក ស្មើនឹង០២គម្រោង
  - ➢ ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា ចំនួន០៦លើក ស្មើនឹង១៥គម្រោង
  - ➢ ប្រជុំវាយតម្លៃប្រគល់១០០ ទទួល-% ការងារឆ្នាំ២០២១ ចំនួន០១ លើក ស្មើនឹង០២ គម្រោង
  - ➢ ប្រជុំវាយតម្លៃបញ្ចប់សុពលភាពការងារឆ្នាំ២០២០ ចំនួន ០៣ លើក ស្មើនឹង ០៧ គម្រោង។

**២.២- អំពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្ត អាណត្តិទី៣ បានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ៣២ លើក។ ដោយបានដាក់ចេញនូវដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្ត ចំនួន ០៨ និងអនុម័តលើឯកសារ មានដូចខាងក្រោម៖

- ដីកា បទបញ្ជាផ្ទៃក្នុង របស់ក្រុមប្រឹក្សាខេត្ត
- ដីកា ស្តីពីប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី៣
- សេចក្តីសម្រេច ស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២១-២០២៣ របស់រដ្ឋបាលខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការលទ្ធកម្មខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការ គ. ក. ស. ក ខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការ សម្របសម្រួលបច្ចេកទេសខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយ៍កម្មខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន របស់គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត
- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាព និងតួនាទី ភារកិច្ចមន្ត្រីទទួលបន្ទុកព័ត៌មានរដ្ឋបាលខេត្ត
- បានពិនិត្យ និងអនុម័ត ពាក្យសុំច្បាប់ឈប់សម្រាក់ជូនសមាជិកក្រុមប្រឹក្សាដែលបានដាក់ពាក្យសុំច្បាប់មុនកិច្ចប្រជុំសាមញ្ញ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- បានពិនិត្យ និងអនុម័តកំណត់ហេតុរាល់កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ក្រុមប្រឹក្សា

- បានពិនិត្យ និងអនុម័ត របាយការណ៍លទ្ធផលការងាររបស់រដ្ឋបាលខេត្ត ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- និងឯកសារផ្សេងៗទៀត ដែលបានដាក់ស្នើសុំការអនុម័តពីក្រុមប្រឹក្សាខេត្ត
- បានអនុម័ត និងធ្វើកាបោះពុម្ព ផ្សព្វផ្សាយ នូវផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល (២០២០-២០២២) ស្របតាមគោលការណ៍ណែនាំ ផ្នែកគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ដែលក្នុងនោះគម្រោងកម្មវិធីអភិវឌ្ឍនមូលដ្ឋានរយៈពេល ៥ ឆ្នាំ របស់ក្រុមប្រឹក្សាខេត្តមានចំនួន ៦២ គម្រោង ដោយបែងចែកជា ០៤ ផ្នែក គឺ ផ្នែកសេដ្ឋកិច្ចចំនួន ៣៨ គម្រោង ផ្នែកសង្គមកិច្ចចំនួន ០៧ គម្រោង ផ្នែកគ្រប់គ្រងធីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយចំនួន ០៣ គម្រោង និងផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសាធារណៈចំនួន ១៤ គម្រោង។

ជាមួយគ្នាផងដែរ ក្រុមប្រឹក្សាបានអនុវត្តតួនាទី ភារកិច្ចដ៏ទៃទៀតដូចជា៖

- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត ពិធីប្រកាស ពិធីសម្ពោធសមិទ្ធផលនានា ពិធីសំណេះសំណាល វគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗ ក្នុងខេត្តចំនួន ១០៧ លើក និងក្រៅខេត្តចំនួន ១៦ លើក
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត សម្រាប់ ឆ្នាំ២០១៩ នៅលើក្រុង ស្រុក ទាំង ០២ ក្នុងខេត្ត ដែលមានអ្នកចូលរួមសរុប ចំនួន ៣៥៨ នាក់ ស្រី ៧០ នាក់ ដោយទទួលបានសំណើ សំណូមពរ ចំនួន ២២ ករណី ក្នុងនោះបានធ្វើការបកស្រាយ និងដោះស្រាយរួចចំនួន២២ ករណីរួចរាល់
- នៅឆ្នាំ២០២១កន្លងទៅ ក្រុមប្រឹក្សាខេត្តគ្រោងនឹងរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្នុងខែមករា ប៉ុន្តែដោយសារស្ថានភាពជំងឺកូវីដ-១៩ និងចំនួនពលករត្រឡប់មកពីប្រទេសថៃច្រើន ត្រូវរៀបចំធ្វើចត្តាឡីស័កទាំងអស់គ្នា ទើបរហូតមកដល់ពេលនេះមិនទាន់បានរៀបចំវេទិកានៅឡើយ
- ក្នុងការបំពេញមុខងារជាក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា បានអនុវត្តក្រមសីលធម៌ របស់ក្រុមប្រឹក្សា រដ្ឋបាលថ្នាក់ក្រោមជាតិ បានល្អស្របតាមសំណុំគោលការណ៍ ដែលបានកំណត់អំពីឥរិយាបថ និងការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា
- គម្រោងវិនិយោគបីឆ្នាំរំកិលខេត្តឆ្នាំ២០២១ មាន៤ផ្នែក សរុប ៥០ គម្រោង
    - ➢ គឺផ្នែកសេដ្ឋកិច្ច មានចំនួន ៣១ គម្រោង បានអនុវត្តបញ្ចប់ចំនួន ០៣ គម្រោង កំពុងអនុវត្តចំនួន ០១ គម្រោង និងមិនទាន់បានអនុវត្តចំនួន ២៧ គម្រោង
    - ➢ ផ្នែកសង្គមកិច្ចមានចំនួន ០៧ គម្រោង បានអនុវត្តបញ្ចប់ចំនួន ០៦ គម្រោង និងមិនទាន់បានអនុវត្តចំនួន ០១ គម្រោង

- ➢ ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ មាន ០១ គម្រោង បានអនុវត្តបញ្ចប់
- ➢ ផ្នែករដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈមាន ១១ គម្រោង បានអនុវត្តបញ្ចប់ចំនួន ០៦ គម្រោង មិនទាន់បានអនុវត្តចំនួន០៥ គម្រោង។ គម្រោងដែលមិនទាន់បានអនុវត្ត គឺគម្រោងមិនមានថវិកាអនុវត្តក្នុងឆ្នាំ២០២១ ដោយការធ្វើវិចារណៈកម្មលើកទី២ កាត់បន្ថយចំណាយដោយសារជំងឺកូវីដ-១៩

- បានចូលរួមជាមួយគណៈអភិបាលខេត្ត ក្នុងការងារប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១ ដោយបានចុះអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩ នៅតាមមូលដ្ឋាន។ ចុះត្រួតពិនិត្យមើលការរៀបចំទីតាំងពិនិត្យសុខភាពនៅតាមព្រំដែននៃប្រទេសថៃ និងតាមមណ្ឌលធ្វើចត្តាឡីស័ក ព្រមទាំងបានចែកអំណោយ និងសំភារៈការពារជំងឺកូវីដ-១៩ ដល់បងប្អូនពលករដែលទើបត្រឡប់មកពីក្រៅប្រទេស ចូលមកក្នុងខេត្តប៉ៃលិន
- បានចូលរួមជាមួយគណៈអភិបាលខេត្ត ក្នុងការបរិច្ចាគថវិកាជូនរាជរដ្ឋាភិបាល ដើម្បីទិញវ៉ាក់សាំងកូវីដ-១៩ និងចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនានា ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមគ្រប់រូបភាពទាំងអស់។

**២.៣-អំពីការគាំទ្រគណៈអភិបាលខេត្ត ក្នុងការអនុវត្តមុខងារកំណែទម្រង់វិមជ្ឈការ វិសហ- មជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ**

តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលក្រុង ស្រុកទាំងអស់ ក្នុងខេត្តប៉ៃលិន បានទទួលការធ្វើសមាហរណកម្ម ការិយាល័យជំនាញនានាជុំវិញ ទៅក្នុងរចនាសម្ព័ន្ធថ្មីដែលមានចំនួនសរុប ៨៣ នាក់។ ការធ្វើប្រតិភូកម្មអំណាចលើការផ្តល់សេវារដ្ឋបាល នៅថ្នាក់ខេត្តមានអង្គភាពច្រកចេញចូលតែមួយ។ ចំណែកនៅថ្នាក់ក្រុង ស្រុក មានការិយាល័យច្រកចេញចូលតែមួយ ដែលបច្ចុប្បន្នកំពុងដំណើរការផ្តល់ សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ធ្វើឱ្យការទទួលសេវាកាន់តែមានលក្ខណៈល្អប្រសើរឡើងគួរកត់សម្គាល់។

ជាមួយគ្នានោះដែរ លើមុខងារ គ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ក្រុមប្រឹក្សាខេត្តបានចូលរួមសហការរៀបចំពិធីផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យដំណើរការមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តប៉ៃលិន កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅ និងកំពុងដំណើរការជាប្រក្រតីដោយពុំមានបញ្ហាអ្វីឡើយ។

**២.៤-វឌ្ឍនភាព នៃការធ្វើគណនេយ្យភាព**

ដើម្បីលើកកម្ពស់ភារកិច្ច ធ្វើគណនេយ្យភាពជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាខេត្តបានយកចិត្តទុកដាក់ធ្វើកិច្ចការមួយចំនួន ដូចខាងក្រោម៖

- កិច្ចប្រជុំក្រុមប្រឹក្សា ពិនិត្យមើលការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ពិសេសការឆ្លើយតបទៅនឹងតម្រូវការសេវាទីក្រុង ទីប្រជុំជន និងសេវាជនបទ
- ពិនិត្យមើលការឆ្លើយតបគ្រោះមហន្តរាយ ធម្មជាតិ និងរោគរាតត្បាតពិសេសជំងឺកូវីដ-១៩
- ជម្រុញអនុវត្តគោលនយោបាយ គណនេយ្យភាពសង្គម តាមរយៈកិច្ចការការិយាល័យប្រជាពលរដ្ឋ ដែលជាយន្តការគណនេយ្យភាព តាមបែបប្រជាធិបតេយ្យ រួមចំណែកប្រាស្រ័យទាក់ទងដោះស្រាយ សម្របសម្រួលទំនាស់នានា ដែលទទួលបានតាមរយៈប្រអប់សំបុត្រ និងពាក្យបណ្តឹងផ្ទាល់ពីប្រជាពលរដ្ឋ។ បច្ចុប្បន្នការិយាល័យប្រជាពលរដ្ឋខេត្ត បានរៀបចំប្រអប់សំបុត្រទទួលពាក្យបណ្តឹង ២០កន្លែង ទទួលពាក្យបណ្តឹងបានចំនួន ១៥ បណ្តឹង ធ្វើការសម្របសម្រួលដោះស្រាយបានចំនួន១២បណ្តឹង កំពុងដំណើរការចំនួន ០១ បណ្តឹង និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន ០៣ បណ្តឹង បានបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយតាមនីតិវិធី។

## ៣-អនុសាសន៍

តាមរយៈកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញក្រុមប្រឹក្សាខេត្តកន្លងមក ក្រុមប្រឹក្សាខេត្ត បានផ្តល់ជាអនុសាសន៍មួយចំនួនជូនដល់គណៈអភិបាលខេត្ត ដើម្បីយកទៅរៀបចំចាត់ចែង និងកែលម្អ ហើយគណៈអភិបាលខេត្តតែងតែបានយកទៅអនុវត្តតាម ដោយបានធ្វើរបាយការណ៍ឆ្លើយតបអំពីលទ្ធផលជាបន្តបន្ទាប់ ក្នុងនោះមានដូចជា ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅតាមទីប្រជុំជន ក្រុង ស្រុក ការការពារ ថែរក្សា ទ្រព្យសម្បត្តិ និង សមិទ្ធផលសាធារណៈ បញ្ហាទំនាស់ផ្សេងៗ នៅមូលដ្ឋាន បញ្ហាអគ្គិសនី និងទឹកស្អាត បញ្ហាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រឡាយទឹក បញ្ហាគ្រោះមហន្តរាយ និងការដោះស្រាយនូវកង្វល់ សំណើ សំណូមពរ របស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលបានលើកឡើង ក្នុងអង្គវេទិកាជាដើម។

## ៤-ទិសដៅអនុវត្តបន្ត

១- បន្តជួយផ្តួចផ្តើមគំនិតជួយដល់គណៈអភិបាលខេត្ត ក្នុងការជំរុញអភិវឌ្ឍសេដ្ឋកិច្ចខេត្ត

២- ចូលរួមផ្តល់យោបល់ និងកំណត់ទិសដៅជូនរដ្ឋបាលខេត្ត ក្នុងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត ជូនប្រជាជនប្រើប្រាស់ និងបម្រើការធ្វើអាជីវកម្ម និងការវិនិយោគផ្សេងៗ

៣- បន្តតាមដាន ត្រួតពិនិត្យមើលការកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា សម្រាប់ចូលរួម ចលនាប្រឡងប្រណាំងទីក្រុងស្អាត និងការទាក់ទាញភ្ញៀវទេសចរ ទាំងក្នុងស្រុក និងបរទេសឱ្យចូលមកកំសាន្តនៅក្នុងខេត្ត

៤- បន្តតាមដាន និងជម្រុញការចុះបញ្ជីដីធ្លីទាំងលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយបញ្ហាទំនាស់ដីធ្លី

៥- ជម្រុញនូវការផ្តល់សេវារដ្ឋបាល និងសេវាសារណៈ ជូនប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ តាមរយៈច្រកចេញចូលតែមួយ នៅគ្រប់លំដាប់ថ្នាក់ទាំងអស់

៦- បន្តពិនិត្យមើលលើការអនុវត្ត ឱ្យបានល្អនូវគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព"

៧- បន្តដោះស្រាយទំនាស់ សំណូមពរ និងកង្វល់ទាំងឡាយរបស់ប្រជាពលរដ្ឋ ដែលបានមកតាមរយៈការធ្វើវេទិការបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់

៨- ពង្រឹងការអនុវត្តវិធានផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ខេត្ត

៩- ពង្រឹងការអភិវឌ្ឍ សមត្ថភាពក្រុមប្រឹក្សា ជាពិសេសការធ្វើទំនាក់ទំនងអន្តររដ្ឋបាល និងទំនាក់ទំនងក្រុមប្រឹក្សាប្រភេទផ្សេងគ្នា។

**៥-អំពីបញ្ហាប្រឈម**

ជាមួយនឹងលទ្ធផលការងារដែលសម្រេច ដូចបានគោរពរាយការណ៍ជូនខាងលើ ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាខេត្តប៉ៃលិន ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

១- មិនទាន់មានធនធានគ្រប់គ្រាន់ ហើយសមត្ថភាពអនុវត្តតួនាទីភារកិច្ចដូចមានចែងក្នុងច្បាប់នៅមានកម្រិត ជាហេតុធ្វើឱ្យក្រុមប្រឹក្សាមិនទាន់អាចបំពេញតួនាទី ឆ្លើយតបបានពេញលេញ តាមតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសំណូមពរនៅឡើយ

២- គណៈកម្មាធិការជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា ថ្វីត្បិតតែបានធ្វើកិច្ចការបានច្រើនក៏ពិតមែន តែក៏នៅមានកិច្ចការមួយចំនួនមិនទាន់អនុវត្តបានតាមស្មារតី នៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានៅឡើយ

៣- លទ្ធភាពនៃការអនុវត្តនូវមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា នៅមិនទាន់បានឆ្លើយតបសមស្របនូវតម្រូវការសេវាសាធារណៈ ទៅតាមស្ថានភាព នៃការវិវត្តន៍ជាក់ស្តែងរបស់សង្គម។ ដូចជានៅទីក្រុងរួមមាន សេវាអនាម័យ បរិស្ថាន សណ្តាប់ធ្នាប់សាធារណៈ... ។ល។ នៅទីជនបទដូចជា សេវាផ្នែកកសិកម្ម គមនាគមន៍ ជារាសាស្ត្រ និងធនធានធម្មជាតិជាដើម។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរព ជូន**ពរឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលមានវត្តមានក្នុងសន្និសារព័ត៌មានថ្ងៃនេះ សូមប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

សូមគោរពអរគុណ !